**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

លេខ ០១១ ស.អ.យ

ថ្ងៃពុធ ២រោច ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥
រាជធានីភ្នំពេញ, ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២១

# សេចក្តីជូនដំណឹងជាសាធារណៈ
## ស្តីពីការប្រកាសស្វែងរកឪពុកម្តាយចិញ្ចឹមក្នុងប្រទេស ឬ អ្នកអាណាព្យាបាលស្របច្បាប់សម្រាប់អនីតិជន

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សូមជូនដំណឹងជាសាធារណៈជូនចំពោះសម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក/លោកស្រីឧកញ៉ា លោក លោកស្រី ដែលមានសញ្ជាតិខ្មែរ និងមានទីលំនៅអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា មេត្តាជ្រាបថា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានកុមារ និងយុវជនកំព្រា ចំនួន ២៨នាក់ ដែលភាគច្រើនជាកុមារ និងយុវជនពិការ និងមានជំងឺប្រចាំកាយ កំពុងរស់នៅក្នុងមជ្ឈមណ្ឌលបុរីទារក និងកុមារជាតិ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួង។ ក្នុងករណី សម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក/លោកស្រីឧកញ៉ា លោក លោកស្រី មានចំណាប់អារម្មណ៍ និងមានបំណងចង់សុំកូនចិញ្ចឹមក្នុងប្រទេស ក៏ដូចជាចង់ផ្សារភ្ជាប់មនោសញ្ចេតនាជាគ្រួសារចិញ្ចឹម ដោយទឹកចិត្តសប្បុរសធម៌ និងក្តីអាណិតស្រលាញ់ចំពោះកុមារកំព្រាណាម្នាក់ ឬធ្វើជាអ្នកអាណាព្យាបាលស្របច្បាប់ក្នុងប្រទេស ចំពោះកុមារ និងយុវជនទាំង២៨នាក់នេះ សូមមេត្តាទំនាក់ទំនងដាក់ពាក្យស្នើសុំជាមួយនាយកដ្ឋានសុខុមាលភាពកុមារ នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដែលមានអាសយដ្ឋាន**អគារលេខ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ឬសូមធ្វើទំនាក់ទំនងតាមទូរស័ព្ទលេខ ០១៥ ៩៧៣ ៥៣៦។**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សូមស្វាគមន៍ជានិច្ចចំពោះសន្តានចិត្ត និងពលីកម្មដ៏ថ្លៃថ្លារបស់សម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក/លោកស្រីឧកញ៉ា លោក លោកស្រី ដើម្បីឧត្តមប្រយោជន៍កុមារ និងយុវជនទាំងនោះ។